សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

Free

# KhmerPost USA

www.khmerpostusa.com

FREE COPIES
Vol. 13. Issue #280
Sept 29, 2019
www.khmerpostusa.com
Office: 978-677-7163
Direct: 978-656-8141
Email:Khmerpostusa@gmail.com


**ព័ត៌មានសំខាន់ៗខាងក្នុង...**


ពិធីកាន់បិណ្ឌទី៥ នៅវត្ត "សាមគ្គីសន្តិការាម *Page 05*



ពិធីបុណ្យសែនព្រះខែ *Page 15*





**ដំណឹងជ្រើសរើសបុគ្គលិក**

អង្គភាពសារព័ត៌មានខ្មែរប៉ុស្ដិ៍ត្រូវការ
ជ្រើសរើសបុគ្គលិកជាច្រើននាក់ផ្នែក
សរសេរភាសាខ្មែរ ប្រសិនបើចេះភាសា
អង់គ្លេសកាន់តែប្រសើរ
បើមានចំណាប់អារម្មណ៍ទំនាក់ទំនង
មកលេខ :

Tel: (978) 656-8141
012 830 889


# លទ្ធផលនៃការបោះឆ្នោតក្រុងឡូវែល២០១៩

ដោយ ពិន សំខុន

អ្នកទៅបោះឆ្នោតនៅឡូវែល ថ្ងៃទី២៤ កញ្ញា នេះមាន៥៥៨៨នាក់ក្នុងចំណោម៥៩០៣០នាក់ដែលបានចុះឈ្មោះ -គឺជាចំនួន៩,៥% ដ៏តិចបំផុត ដែលបានប្រើសិទ្ធិខ្លួនជាពលរដ្ឋអាមេរិកាំង។ តែគេក៏អាចយល់បានដែរថា នៅលើកនេះ ដោយសារពលរដ្ឋនឹងជម្រុះបេក្ខជនតែ២នាក់ នឹងមានសារៈសំខាន់តិចជាងការបោះឆ្នោតជុំទី២ នៅថ្ងៃទី៤ខែវិច្ឆិការខាងមុខ ដែលនឹងត្រូវជម្រុះបេក្ខជនដល់ទៅ៩រូប។ ទោះជាចំនួនអ្នកទៅបោះឆ្នោតតិចក៏ដោយ គេក៏អាចប៉ាន់ប្រមាណថាអ្នកដែលទទួលបាននូវសន្លឹកឆ្នោតដំបូងគេ៩រូប នឹងមានសំណាងច្រើននៅក្នុងការបោះឆ្នោតជុំទី២ នៅក្នុងចំនួននោះ មានបេក្ខជនខ្មែរ-២៥៦៧ គឺច្រើនជាងគេបង្អស់ គឺ វាសនា នួន - ចំណែកឯបេក្ខជនខ្មែរ-អាមេរិកាំងទី៣ គឺ ថាយ ជុំ តទៅទំព័រទី ០២



សុខា វីចៅ លំដាប់លេខ៧



ថៃ ជុំ លំដាប់លេខ១២



វាសនា នួន ជាប់ឆ្នោតលំដាប់លេខ១

## Vesna Nuon topped the ticket in Lowell City Council preliminary election

By Soben Pin

Lowell, MA — Vesna Nuon topped the ticket in Lowell City Council prelmimarny election on Tuesday, September 24. "I'd like to thank you our brothers and sisters for coming out to vote for me and I ask for their continued support in the general election on Tuesday, November 5. We must join our hands together to be strong" said Nuon.

*Continued to Page 02*




**មេធាវី លុយ ហាស្កែល** **LAW OFFICE OF LOUIS S. HASKELL**

សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987

គ្រោះថ្នាក់ចរាចររថយន្តតូច, រថយន្តធំ និងម៉ូតូ • អន្តោប្រវេសន៍
ធ្វើពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ
ដំណោះស្រាយ និងការពារបញ្ហាពន្ធដា

សូមអរគុណចំពោះការបន្តទុកចិត្តរបស់លោកអ្នកមកលើការិយាល័យមេធាវីយើងខ្ញុំ ក្នុងការដោះស្រាយ
បញ្ហាផ្នែកច្បាប់ និងពន្ធដារជូនលោកអ្នក ។ យើងខ្ញុំរំពឹងថា នឹងបម្រើលោកអ្នកយ៉ាងល្អនាពេលអនាគត។
បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ

*Excellent Service Since 1987*

Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense

*Thank you for your continued confidence*
*In our office to handle your legal and tax matters.*
*We look forward to serving you well into the future.*

16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com

តមកពីទំព័រទី ០២

# លទ្ធផលនៃការបោះឆ្នោតក្រុងឡូវែល

បានចំណាត់ថ្នាក់ទី១២ គឺត្រូវតែស្វែងរកការគាំទ្រឱ្យរឹតតែខ្លាំងជាងមុន។ មើល ទៅអភិបាលក្រុង ប៊ីល សាម៉ារ៉ាស វិញ ឋិតនៅចំណាត់ ថ្នាក់ទី៩ ។

ចំណែកឯបេក្ខជន រីតា មើស្សៀ នឹង រ៉តនីយ អេលីយ៉ុត នៅតែជាចំណូលចិត្តខ្ពស់របស់ពលរដ្ឋឡូវែលដដែល។ នៅមានបេក្ខជនអតីតក្រុមប្រឹក្សារំលងអាណត្តិមុន២រូប គឺ ដាន់ រួក (ថ្នាក់លេខ៤) នឹង កូរីបេឡិនជ័រ(ថ្នាក់លេខ៨) ក៏ត្រឡប់មកប្រកួតយកដំណែងចាស់របស់ខ្លួនយ៉ាងប្រឹងប្រែង ។

ខាងក្រោមនេះជាឈ្មោះបេក្ខជន ដែលបានជាប់ឆ្នោតទាំង១៨នាក់ តាមលំដាប់ថ្នាក់នៃចំនួនសន្លឹកឆ្នោត:

1-Veasna Nuon
2-Rita M.Mercier
3-Rodney Elliott
4-Daniel Rourke
5-John Drinkwater
6-John J.Leahy
7-Sokhary Chau
8-Cory A.Belanger
9-William Bill Samaras
10-Martin Marty Lorry
11-David M.Ouellette
12-Ty Chum
13-Karen A.Cirillo
14-David J.Conway
15-Jeffrey L.Thomas
16-Harry Kortikere
17-Juan C.Castaneda
18-A.Ampero-Del Villar

នៅថ្ងៃទី៥វិច្ឆិកា ២០១៩ នឹងមានការបោះឆ្នោតសាកលសម្រាប់១-ក្រុមប្រឹក្សាក្រុងនឹងសម្រាប់ ២-គណកម្មការសាលារៀនជាមួយគ្នា ព្រមទាំងមាន ៣-"សំនួរប្រជាមតិ"អំពីរបៀបបោះឆ្នោតក្រុមប្រឹក្សាក្រុង ចាប់ពីឆ្នាំ២០២១ នៅឡូវែល



From left to right: Rithy Ung, Mayor William Samara, Vice Mayor Vesna Nuon and Bophadevy Peou on the election day.

ដែលសូមឱ្យពលរដ្ឋតាមដាន ដើម្បីយល់ដឹងឱ្យបានច្បាស់មុននឹងសម្រេចគូសយកប្រព័ន្ធបោះឆ្នោតណាមួយនោះ។

# Lowell's Cambodian / *From Front Page*

Nuon served one term as city councilor from 2012-2013, and currently serving as Vice Mayor. He also had earned the top ticket in the last election cycle.

This election has two open council seats. Councilor Jim Millinazzo decided not to seek the re-election and councilor Ed Kennedy was elected as State Senate in the last fall. Consequently, we have at least 2 new councilors to be elected in this race, assuming if all incumbents will be re-elected.

Two other Cambodian American candidates are including Ty Chum, the first time candidate and finished 12, and Sokhary Chau, previously ran unsuccessfully in 2017, finished 7.

Here is the summary for preliminary results for all 20 candidates by top ticket earner's name and amount of total votes each received on Tuesday, September 23rd, 2019

Vesna Noun, 2,567
Rita M. Mercier 2,560
Rodney M. Elliott 2,236
Daniel P. Rourke 2,159
John Drinkwater 1,983
John Leahy 1,982
Sokhary Chau 1,864
Corey Belanger 1,840
William Bill Samara 1,784
Martin Marty Lorrey 1,663
David M. Ouellette 1,579
Ty Chum 1,531
Karen A. Cirillo 1,494
David J. Conway 1,442
15. Jeffrey L. Thomas 1,136
Harry Kortikere 943
A. Amparo-Delvillar 887
Juan C. Castaneda 880
Martin J. Hogan 809
Jose W. Negron 752

Because there are 20 candidates, two candidates received the least votes are eliminated in the preliminary election. Top 18 vote getters are going into the general election in November. 9 highest bidders will serve in the 2020-2021 council term. General election be held on Tuesday, November 5, 2019.



# ហាងលក់រថយន្ត ដេវីដ អូតូសែល

## បង្កើតនូវសេចក្តីស្រលាញ់រាប់អានជាមួយយើងខ្ញុំ







•មិនមានក្រេឌីត •មានក្រេឌីតមិនល្អ •គ្មានបញ្ហា!

# David Auto Sales

93 Chelmsford St, Lowell, MA 01851

យើងខ្ញុំមានលក់ និងអាចដឹកជញ្ជូនឡាន ម៉ូតូ គ្រឿង បន្លាស់
និងរបស់ប្រើប្រាស់ផ្សេងៗរបស់លោកអ្នកទៅកាន់ប្រទេសកម្ពុជា
តាមរយៈក្រុមហ៊ុន David Auto Export
ទីតាំងទទួលការដឹកជញ្ជូន គឺស្ថិតនៅផ្លូវលេខ 93 Chelmsford
St. Lowell, MA និងនៅឃ្លាំងរបស់យើងខ្ញុំមានទីតាំងនៅ
Cranston, Rhode Island ។ មកកាន់កន្លែងយើងខ្ញុំ
រឺទូរស័ព្ទសម្រាប់ព័ត៌មានបន្ថែមតាមលេខ

**978-786-7777 | 978-996-2129**

អ្នកលក់រថយន្តជនជាតិខ្មែរតែមួយ
នៅញូ អ៊ីងលិន!

យើងខ្ញុំសូមស្វាគមន៍អតិថិជនថ្មី! នៅហាងលក់ឡានដេវិត យើងខ្ញុំខិតខំធ្វើការយ៉ាងយកចិត្តទុកដាក់បំផុត តាមតម្រូវការរបស់អតិថិជន ដើម្បីទទួលការជឿទុកចិត្តពីអតិថិជនលើសេវាកម្ម និងគុណភាពដែលអតិថិជនចង់បាន។

សូមអរគុណ!
ក្រុមការងារផ្នែកលក់ហាងដេវីត

**បើកលក់ 7 ថ្ងៃក្នុង**
**មួយសប្តាហ៍** 10AM - 7PM

សូមទាក់ទងលោកដេវីត (David) **978-996-2129**

# គ្រោះថ្នាក់ចរាចរណ៍ទូទាំងប្រទេសរយៈពេល៣ថ្ងៃ នៃពិធីបុណ្យភ្ជុំបិណ្ឌឆក់យកជីវិតមនុស្ស២៦នាក់ និង៨០នាក់រងរបួស

ភ្នំពេញៈ យោងតាមរបាយការណ៍ ពីអគ្គស្នងការដ្ឋាននគរបាលជាតិបានឱ្យដឹងថា រយៈពេល៣ថ្ងៃ ពោលចាប់ពីថ្ងៃទី២៧-២៩ ខែកញ្ញា ឆ្នាំ២០១៩ នៃពិធីបុណ្យភ្ជុំបិណ្ឌមានករណីគ្រោះថ្នាក់ចរាចរណ៍ នៅទូទាំងប្រទេសសរុបចំនួន៥២លើកបណ្ដាលឱ្យមនុស្សស្លាប់២៦នាក់ របួសស្រាល២៨នាក់ និងរបួសធ្ងន់៥២នាក់។

ប្រភពព័ត៌មានដដែលបញ្ជាក់ថា នៅក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ទាំង៥២លើកនេះ បណ្ដាលឱ្យខូចខាតម៉ូតូចំនួន៦៦គ្រឿង, រថយន្តតូច២៤គ្រឿង, រថយន្តធំ៣គ្រឿង ហើយមូលហេតុដែលបណ្ដាលឱ្យកើតមានគ្រោះថ្នាក់ចរាចរណ៍ រួមមានៈ ល្បឿន, មិនគោរពសិទ្ធិ, មិនប្រកាន់ស្ដាំ, ប្រជែង, បត់គ្រោះថ្នាក់ និងស្រវឹង។ FreshNews












# ពិធីកាន់បិណ្ឌទី៥នៅវត្ត"សាមគ្គីសន្តិការាម"

ដោយ ពិន សំខុន

ថ្ងៃទី១៨កញ្ញានេះ ជាថ្ងៃប្រារព្ធពិធីកាន់បិណ្ឌទី៥ នៅតាមវត្តអារាមនានា គឺត្រូវនឹងថ្ងៃពុធ ៥រោចខែភទ្របទ ឆ្នាំ២៥៦៣ នៃពុទ្ធសករាជ្យ។ លោកធូ សារឿន ជាអាចារ្យវត្ត"សាមគ្គីសន្តិការាម"ព្រមទាំងភរិយាគាត់ រួមទាំងបាសកជើងវត្ត៤-៥នាក់ទៀត ជាអ្នករកាន់បិណ្ឌ រួមនាថ្ងៃនោះ តាមគម្រោងកាន់បិណ្ឌលំដាប់លំដោយ បន្តបន្ទាប់គ្នាម្នាក់ម្តង ចំនួន១៥ថ្ងៃ ដែលនៅចុងបញ្ចប់ នោះគេហៅថា"ថ្ងៃភ្ជុំបិណ្ឌ"ដែលតែងប្រារព្ធជាពិធីបុណ្យធំបំផុត ប្រចាំឆ្នាំ នាគ្រប់វត្តអារាមខ្មែរ។

ពុទ្ធសាសនិកនាំគ្នាស្លៀកពាក់ស្អាតៗមកកាន់ទីវត្ត ទាំងគ្រួសារយកចង្ហាន់រៀបចំជាប្រណិតយកស្បង់ជីពរថ្មីៗ បារីស្លាម្លូរ នឹងតែស្ករ ចងជាកញ្ចប់ ទៅវេរប្រគេងព្រះសង្ឃ ខ្លះទៀតក៏នាំយកភេសជ្ជមានទឹកបរិសុទ្ធ ឬក៏អង្ករ ឬក៏សម្ភារទៀនធូប ដែលទាំងអស់នោះបង្ហាញថា "ក្នុងវប្បធម៌ខ្មែរប្រជាពលរដ្ឋមានសទ្ធាជ្រះថ្លាខ្លាំងណាស់ រួមកម្លាំងជួយផ្គត់ផ្គង់ជីវភាពព្រះសង្ឃនឹងវត្តអារាម"ឱ្យគង់វង្សស្ថិតបេវរីកចំរើនមិនឱ្យខ្វះខាតឡើយ។ ទាំងនេះ ដោយសារតែគេជឿថា មាននរកប្រែតបានត្រូវគេដោះលែងពីឋាននរកឱ្យមករកចំណីនៅឋានកណ្តាល នាអម្លុងពេលនេះ ពីព្រោះតែទទួលបាបកម្មបានត្រូវឃោមបាលបង្អត់អាហារជាយូរឆ្នាំ-នរកនឹងប្រែតទាំងនោះ អាចជាញាតិសណ្តានជាមិត្រភក្តិនៃឧបាសកឧបាសិកាជើងវត្ត ឬក៏នៃអ្នក



ព្រះសង្ឃទទួលចង្ហាន់ពីពុទ្ធបរិស័ទ



អាចារ្យ ធូសារឿន និងភរិយា អរគុណពុទ្ធិរស័ទដែលបានចូលរួមកាន់បិណ្ឌទី៥

ស្រុកគ្រប់រូប ដូច្នេះកុសលផលបុណ្យដែលកើតពីសទ្ធានៃការប្រគេនចង្ហាន់នឹងទេយ្យទានចំពោះព្រះសង្ឃ ក៏បានឆ្លងទៅប្រគល់ជូនដល់សណ្តានទាំងអស់នោះ ដូចក្តីបំណងបាន។

ក្រុមចាស់ទុំ ដែលតែងតែជួបជុំគ្នា នាតុកាហ្វេនៅឡូវែល ក៏បានណាត់គ្នាទៅចូលរួមជាកិត្តយសដល់ពិធីកាន់បិណ្ឌលោកអាចារ្យ ធូ សារឿន នាថ្ងៃដ៏ពិសេសនោះដែរ ពីព្រោះលោកតាសារឿន ក៏ឧស្សាហ៍មកចូលរួម ពីសារកាហ្វេរជជែកលេងជាមួយចាស់ៗ ដែលខ្លះចូលនិវត្តន៍ទៅហើយ ខ្លះទៀត ក៏នៅពេញកម្លាំងកំពុងប្រកបរបរជាការងារលុយសុទ្ធ ឬលុយសែកនៅឡើយ, ហើយចងគ្នាជាមិត្រ នៅតុកាហ្វេនោះតាំងពីប្រមាណជា២០ឆ្នាំមកហើយ។ ចាស់ទុំទាំងនោះ ក៏ជាពុទ្ធសាសនិកដ៏ជ្រៅជ្រះដូចគេឯងដែរ ទៅធ្វើបុណ្យនៅគ្រប់វត្តនៃឡូវែលស្រាក់លុយគ្នាធ្វើការដាក់ទានជាញឹកញាប់ដល់ជនក្រីក្រ ឬជនរងគ្រោះនៅក្នុងតំបន់ឬក៏នៅកម្ពុជា, ជាពិសេសតែងតែជាអ្នកជួយជ្រោមជ្រែងដល់ក្រុមគ្រួសារដែលទើបនឹងមកដល់ថ្មីឱ្យមានការកក់ក្តៅនឹងរកសេចក្តីត្រូវការរបស់គ្រួសារខ្លួនបានផង ។

លោកអាចារ្យសារឿនបាននិយាយថា"ប្រមូលបច្ច័យនាថ្ងៃកាន់បិណ្ឌទី៥នោះបានជាង$២៥០០ ប្រគេនព្រះសង្ឃ នឹងឥវ៉ែតវ៉ាន់យ៉ាងច្រើនសម្រាប់ដាក់វត្ត "លោកបន្តថា"ផ្តាំសូមអរគុណដល់ទាំងអស់គ្នា ដែលបានមកចូលរួមកាន់បិណ្យជាមួយខ្ញុំ ហើយជូនឱ្យប្រកបតែសេចក្តីសុខគ្រប់ប្រការ" ។





មណ្ឌលពិនិត្យសុខភាពលីន
Lynn Primary Care Center
លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.
Sokharith Mey, M.D.
ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី
Now Accepting New Patients
អាស័យដ្ឋាន
280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755
ទទួលយកម៉ាសហេ៊ល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

ជំងឺទូទៅ
Family Medicine
សុខភាពផ្លូវចិត្ត
Behavioral Health
We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer

# រ៉ូដអាយឡិនៈ  អគ្គមេធាវីរដ្ឋនឹងគណកម្មការ សិទ្ធិមនុស្សរកយុត្តិធម៌ឱ្យសហគមន៍ខ្មែរ

ខ្មែរផុសស.រ.អា.

នៅក្នុងការផ្សព្វផ្សាយមួយថ្ងៃ១២កញ្ញានេះ ដែលអញ្ជើញសហគមនិខ្មែរឱ្យមកយកប្រាក់សំណង ពីបណ្ដឹងមួយពីការរំលោភច្បាប់នឹងរំលោភសិទ្ធិមនុស្ស ដោយក្លឹប "ព័រទូយគ្គេ" មួយនៅរ៉ូដអាយឡិន, ដែលបានតម្រូវឱ្យអតិថិជនដែលជាខ្មែរ ឱ្យទៅជួលភ្នាក់ងារប៉ូលីសច្រើនរូបឱ្យមកកាពារពិធីមង្គលការកូនចៅ ពិធីបង្កក់កំណើតកូន ឬក៏ពិធីជប់លៀងកូនក្ដួយជាប់សញ្ញាប័ត្រ...។ល។ ករណីនេះមិនបានកើតឡើងចំពោះភ្ញៀវនៃសហគមន៍ដ៏ទៃទេ។ ការិយាល័យអគ្គមេធាវី អេរិន វេសម៉ាន់ បានប្ដើមការស៊ើបអង្កេតជាមួយអង្គការសិទ្ធមនុស្សនៅឆ្នាំ២០១៧ បានប្រទះឃើញថា ជានយោបាយរបស់ក្លឹប ដែលមានទម្លាប់ហៅរកកងកម្លាំងប៉ូលីសក្រុង "ក្រេងស្តុន" ហើយម្ចាស់កម្មវិធីជាអ្នកបង់ប្រាក់ឈ្នួលទៅឱ្យម្ចាស់នៃក្លឹប ករណីនេះ បានធ្វើឱ្យក្លឹបក្លាយជាអ្នករំលោភច្បាប់រដ្ឋផង នឹងកាទិកាសញ្ញានៃសិទ្ធិមនុស្សផង តាំងពីយូរឆ្នាំមកហើយ។


លោក អេរិន វេសម៉ាន់ អគ្គមេធាវី

លោកសែមនៃសមាគមនខ្មែរនៅរ៉ូដអាយឡិន បាននិយាយថា ខ្មែរជាច្រើនបានទៅជួលក្លឹបព័រទុគ្គេនោះ ដើម្បីធ្វើពិធីនានា តែម្ចាស់ក្លឹបគេបានតម្រូវឱ្យភ្ញៀវយកកងការពារខាងប៉ូលិសមកការពារសន្តិសុខចំនួន៥-៦-នាក់ ក្នុងតម្លៃប្រមាណ ៥០ដុល្លារ ក្នុងមួយនាក់។ សមាគមខ្មែរយើងមិនបានទៅធ្វើពិធីអ្វីនៅទីនោះទេ ថ្វីត្បិតតែខ្មែរជាច្រើនចូលចិត្តរៀបចំពិធីជប់លៀងរាំកំសាន្តនៅក្លឹបព័ទុយគ្គេនោះក្ដី តែម្ចាស់ក្លឹបតែងសំអាងថា "ធ្វើនេះដើម្បីជាសវាងការវាយតប់គ្នាក្នុងក្លឹប"។ ម្ចាស់ក្លឹបបាននិយាយប្រាប់អគ្គមេធាវី ថា "ខ្លួនធ្វើនេះ ក៏ធ្វើតាមតែសេចក្ដីណែនាំរបស់ការិយាល័យប៉ូលីសតាំងតែពីឆ្នាំ១៩៩០មកតែប៉ុណ្ណោះ"។

សេចក្ដីរាយការមួយរបស់គណកម្មការសិទ្ធិមនុស្សលោក ម៉ាយកិល អេវូរា និយាយថា "យើងរីករាយនឹងសហការជាមួយអគ្គមេធាវីលើប្រធានបទរើងអើងចំពោះជាតិសាសន៏ឱ្យបានច្រើនទៀត ហើយស្នើទៅក្រសួងយុត្តិធម៌ឱ្យជួយការិយាល័យប៉ូលីសដោះស្រាយផ្នែកបច្ចេកទេសប្រើកងប៉ូលីសជៀសវាងការរំលោភច្បាប់ជំពូក៦ នឹងសិទ្ធមនុស្សបន្ថែមទៀតដែរ"។

ក្លឹបព័រទុយគ្គេ បានទទួកស្គាល់ពីការរំលោភច្បាប់រដ្ឋនឹងច្បាប់សិទ្ធពលរដ្ឋឆ្នាំ១៩៦៤ ហើយសុខចិត្តសងការខូចខាតដល់ប្រជាពលរដ្ឋដើមកំណើតខ្មែរ ដោយគិតចាបតាំងពីខែធ្នូឆ្នាំ២០០៥មក ហើយថែមទាំងផ្សព្វផ្សាយលិខិតសុំទោសជាសាធារណ ចំពោះប្រជាពលរដ្ឋដើមកំណើតខ្មែរផង។ ប្រជាពលរដ្ឋសហគមន៏ខ្មែរនៅរ៉ូដអាយឡិន អាចនឹងទាក់ទងទៅនឹងគណកម្មការសិទ្ធមនុស្សបាន តាមទូរស័ព្ទលេខ ៤១០-២២២ ៤៤៧៧ ។




## តើអ្នកជាសាសន៏ខ្មែរឬ?



**Are you Cambodian?**

ដោយសារអ្នកធ្លាប់បានប្រារព្ធពិធី
នៅគ្រេងស្តុន "ផតទូហ្គីក្លឹប"
លោកអ្នកអាចនឹងទទួលសំណងមួយ
សូមទាក់ទងទៅគណកម្មការសិទ្ធិមនុស្ស
នៅរ៉ូដអាយឡិនៈ

Held an event at the Cranston Portuguese Club ?

You may be entitled to compensation.

Contact the RI Commission for Human Rights:

Francis.Gaschen@richr.ri.gov
**402-222 4477**
Jack.Gamble.int@Richr.ri.gov
**401-222 7563**

# ឈឺទ្រូងជាសញ្ញានៃជម្ងឺគ្រោះថ្នាក់ ដែលអ្នកមិនត្រូវមើលរំលង

ឈឺទ្រូងខាងឆ្វេង អាចជាសញ្ញាដំបូងនៃជម្ងឺបេះដូង សួត ក្រពះ។ល។ ហើយបើសិនមិនយកចិត្តទុកដាក់ជម្ងឺទាំងនេះ អាចសម្លាប់អ្នកបានក្នុងរយៈពេលខ្លី ពិសេសគឺជម្ងឺបេះដូង។

ជម្ងឺបេះដូង គឺជាមូលហេតុសំខាន់មួយដែលបណ្តាលឱ្យមានមនុស្សស្លាប់ច្រើនក្នុងពិភពលោក។ មិនត្រឹមតែមនុស្សដែលមានបញ្ហាបេះដូងពីកំណើត សូម្បីតែមនុស្សដែលមានកម្លាំងមាំមួន ក៏អាចកើតជម្ងឺនេះ ហើយពេលខ្លះអ្នកជម្ងឺបានមើលរំលងអាការៈដំបូងនេះ នាំឱ្យពួកគេមានការប្រឈមនឹងជម្ងឺដ៏កាចសាហាវ។

ការឈឺទ្រូង ជាអាការៈមួយដែលតែងត្រូវបានអ្នកជម្ងឺរអ៊ូរទាំប្រាប់គ្រូពេទ្យ នៅពេលពួកគេទៅពិនិត្យបេះដូង ប៉ុន្តែមិនមែនមានន័យថា រាល់អ្នកជម្ងឺឈឺទ្រូង គឺសុទ្ធតែមានបញ្ហាបេះដូងនោះដែរ។

ជម្ងឺបេះដូង-ការឈឺទ្រូងដែលមានលក្ខណៈដូចជាត្រូវគេសង្កត់ច្របាច់នៅកណ្តាល ឬងាកមកខាងឆ្វេងនៃដើមទ្រូងបន្តិច និងមានរយៈពេលចាប់ពី៣០នាទីឡើងទៅ ដោយមិនមានភាពធូរស្រាលពេលដេកសម្រាក ឬប្រើថ្នាំ ណិតរ្យូងលយចរិនេ នោះគេត្រូវគិតដល់បញ្ហាគាំងបេះដូង។

ការឈឺទ្រូងដែលកើតឡើងដោយសារខ្វះឈាមបេះដូង,ខ្លាញ់ក្នុងសរសៃឈាមបេះដូង (ischemic heart disease) តែងតែរាលដាលមកកាន់ដៃឆ្វេង តែវាក៏អាចរាលដាលដល់ដៃស្តាំ ឬស្មារ ក ខ្នង និងចុងដង្ហើម។

ជម្ងឺក្រពះ-បើសិនការឈឺ ចុក ក្រោយពីហូបអាហារ ផឹកទឹក ផឹកស្រា នោះភាគច្រើន គឺដោយសារជម្ងឺក្រពះ។ ក៏ប៉ុន្តែមានករណីមួយចំនួនការឈឺបែបនេះ ក៏អាចបណ្តាលមកពីបញ្ហាខ្វះឈាមបេះដូងផងដែរ។

តាមធម្មតា អាការៈឈឺចុកដោយសារជម្ងឺខ្វះឈាមបេះដូង ឬខ្លាញ់ក្នុងសរសៃឈាមបេះដូង វានឹងធូរស្រាលមកវិញ បន្ទាប់ពីបានលេបថ្នាំ Nitroglycerine ឬសម្រាកប៉ុន្មាននាទី៣-៥នាទី។ ផ្ទុយទៅវិញ បើសិនឈឺក្រពះ ឬបំពង់អាហារ វានឹងមិនងាយធូរស្រាល ឬធូរស្រាលដែរ តែប្រើពេលយូរ។

ជម្ងឺសួត-ឈឺចាប់ភ្លាមៗដូចទៅនឹងត្រូវចុងកាំបិត ហើយវានឹងឈឺខ្លាំងឡើងនៅពេលដកដង្ហើមចូល ឬពេលដេកផ្ងារ នោះគឺអាចបណ្តាលមកពីរលាកសួត។ ជាងនេះ អាការៈខាងលើក៏អាចបណ្តាលមកពីបញ្ហារលាកស្រោមបេះដូង (pericardium) ក៏ថាបាន។

នៅពេលមានអាការៈឈឺទ្រូងខាងឆ្វេង សូមកុំមើលស្រាល អ្នកគួរទៅពិនិត្យសុខភាពដើម្បីឱ្យដឹងថា អ្នកមានជម្ងឺបេះដូងឬអត់ និងដើម្បីព្យាបាលឱ្យទាន់ពេលវេលា។ នៅកន្លែងពិនិត្យសុខភាពអ្នកអាចនឹងត្រូវបានពិនិត្យសួតដោយកាំរស្មីអិច ពិនិត្យបេះដូងដោយការវាស់ចង្វាក់បេះដូង (ECG) និងអ្កូបេះដូង និងសុងក្រពះដើម្បីឱ្យដឹងថា អ្នកមានជម្ងឺក្រពះឬអត់។ ក្រៅពីនេះ អ្នកក៏ នឹងត្រូវបានបូមឈាមយកទៅពិនិត្យរកជម្ងឺផ្សេងៗដែលពាក់ព័ន្ធផងដែរ។








## 6 មូលហេតុ ដែលត្រូវចូលរួម

- គ្មានការបង់ប្រាក់ជាមុន-រហូតទៅ
- សេវាពេទ្យធ្មេញ ដែលមិនមែនជាចំណាយរបស់អ្នក
- Healthy You Card ដើម្បីទិញ អ្វីខ្លះដែលទាក់ទងនឹងសុខភាព *(អ្នកទទួលបាន $100 ក្នុងមួយឆមាស រហូតដល់ $400 ក្នុងមួយឆ្នាំ)*
- ចូលជាសមាជិក YMCA ឥតគិតថ្លៃ ចំនួនមួយខែចំពោះសមាជិកក្លឹបហាត់ប្រាណ $55 ក្នុងមួយខែ
- អត្ថប្រយោជន៍ទាំងអស់នាពេលបច្ចុប្បន្នរបស់អ្នកពីកម្មវិធីម៉ាស់ហិល MassHealth
- ការធ្វើដំណើរទៅមកពីកន្លែងណាត់ជួបពិនិត្យសុខភាព*




SWH
SENIOR WHOLE HEALTH®
Simple. Secure. Independent.

សម្រាប់ព័ត៌មានបន្ថែម ហៅទូរស័ព្ទ៖
1-888-566-3526 (TTY 711)
www.seniorwholehealth.com/SNP
ម៉ោង 8 ព្រឹកដល់ម៉ោង 8 យប់7
ថ្ងៃក្នុងមួយសប្តាហ៍។

សូមរក្សាទុកអត្ថប្រយោជន៍ពីកម្មវិធីម៉ាស់ហិល MassHealth របស់អ្នកទាំងអស់ បូកជាមួយអ្វីដែលពួកបន្ថែមចូលទៀត

ប្រសិនបើអ្នកមាន MassHealth Standard តែពុំមានការធានា Medicare ផ្នែក A និង/ឬ ផ្នែក B ទេ អ្នកអាចនឹងមានសិទ្ធិចុះឈ្មោះក្នុងកម្មវិធី MassHealth Senior Care Options (SCO)។

*Senior Whole Health គោរពតាមច្បាប់ស្តីពីសិទ្ធិពលរដ្ឋសហព័ន្ធ ដែលត្រូវបានអនុវត្ត និងមិនរើសអើងពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត អាយុ ពិការភាព ឬភេទឡើយ។ ជូនដំណឹង៖ ប្រសិនបើលោកអ្នកនិយាយភាសាក្រៅពីភាសាអង់គ្លេស អ្នកអាចប្រើសេវាជំនួយភាសាឥតគិតថ្លៃបាន។ ហៅទូរស័ព្ទមក 1-888-794-7268 (TTY 711)។ ATENCIÓN: si habla español, tiene a su disposición servicios gratuitos de asistencia lingüística. Llame al 1-888-794-7268 (TTY 711)។ ATENÇÃO: Se fala português, encontram-se disponíveis serviços linguísticos, grátis. Ligue para 1-888-794-7268 (TTY 711)។*
Senior Whole Health (HMO SNP) និង Senior Whole Health NHC (HMO SNP) គឺជាផែនការថែទាំសម្របសម្រួលជាមួយនឹងកិច្ចសន្យាអត្ថប្រយោជន៍ Medicare និងកិច្ចសន្យាជាមួយសហធនម៉ាសាជូសេត/កម្មវិធីសុខភាពសាធារណៈ: EOHHS MassHealth។ ការចុះឈ្មោះអាស្រ័យលើការបន្តកិច្ចសន្យារាល់ឆ្នាំ។ ផែនការនេះមានសម្រាប់អ្នកដែលមានអាយុលើសពី65 ឆ្នាំ ឬចាស់ជាងដែលមានទាំងជំនួយវេជ្ជសាស្ត្រពីរដ្ឋ និង Medicare ឬ Medicaid តែប៉ុណ្ណោះ។ H2224-2018_70986_M_KHM បានអនុម័ត 11/2/2018 ** អាចនឹងមានការដាក់កម្រិត*

# មណ្ឌលពិនិត្យសុខភាពឡូវែល

# Lowell Primary Care Center

លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, **M.D.**

**Sokharith Mey, M.D.**

លោក ចាន់ ទូច , **C.N.P.**

**Chhan Touch, C.N.P.**





ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

**Now Accepting New Patients**

ជំងឺទូទៅ

***Family Medicine*** &

សុខភាពផ្លូវចិត្ត

***Behavioral Health***

អាស័យដ្ឋាន

**1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992**

ទទួលយកម៉ាសហ៊ែល មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត

បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances

Our Staff Speaks Khmer • Plenty of Free Parking

# វេទិកាសាធារណៈរបស់លោក សម រង្ស៊ី នៅឡូវែលរដ្ឋម៉ាសាឈូសេត

**ដោយ ពិន សំខុន**

...វេទិការសាធារណរបស់លោក សម រង្ស៊ី ប្រធានស្តីទីគណបក្សសង្គ្រោះជាតិ នៅឡូវែលថ្ងៃទី ១៤កញ្ញា វេលាម៉ោង៣ល្ងាច -គឺប្រព្រឹត្តទៅដោយគ្មានវត្តមាន សម រង្ស៊ី នឹងដោយគ្មានដំណឹងជាមុន។

ភ្ញៀវកិត្តិយសមានអភិបាលក្រុងនឹងអភិបាលក្រុងរងឡូវែល រួមទាំងមន្ត្រីថ្នាក់លើនៃគណបក្សសង្គ្រោះជាតិ នឹងគណបក្សផ្សេងទៀត( បើតាមសម្តីពិធីករ ទំនងជាមកពីគណបក្សប្រជាជន) ភ្ញៀវជាសមាជិកគណបក្សលោក សម រង្ស៊ី ទាំងអស់មកពីប្រទេសក្រៅនឹងរដ្ឋ ឬតំបន់ក្រៅបានមកពេញហៀរសាលប្រជុំ ដែលមានចំណុះជាង២០០នាក់ រាប់ទាំងអ្នកនៅឡូវែលខ្លះៗនោះ ។ បើតាមសម្តីអ្នកធ្វើអត្ថាធិប្បាយមិនមានសមាជិកសង្គ្រោះជាតិខាងលោកប្រធាន កឹម សុខា ចូលរួមទេ មកអង្គុយទស្សនាសុន្ទរកថាលោក សម រង្ស៊ី "អនឡាញ"ដែលមានន័យស្នេហាជាតិមិនខុសពីពេលមុនៗទេ គឺលោកនឹងវិលត្រឡប់ទៅកម្ពុជាវិញ ថ្ងៃទី៩ វិច្ឆិកា ២០១៩ ខាងមុខ ដើម្បីដឹកនាំប្រជារាស្ត្របះបោរទៅចាប់លោក ហ៊ុន សែន បច្ចុប្បន្នជានាយករដ្ឋមន្ត្រីខ្មែរនឹងប្តូរការគ្រប់គ្រងពីអំណាចផ្តាច់ការ ។

វាគ្មិនកិត្តិយសបន្តរបន្ទាប់ បានមកសម្តែងការប្តេជ្ញាចិត្តជាប្រវត្តិសាស្ត្រ( បន្ទាប់ពីអភិបាលក្រុងប៊ីល សាម៉ាវ៉ាស លាចាកពីសាលប្រជុំ) នៅចំពោះមុខអ្នកស្តាប់ទាំងអស់យ៉ាងមាំទាំថា "នឹងចេញទៅកម្ពុជា រួមដំណើរជាមួយលោក សម រង្ស៊ី" មានទាំងគណកម្មការដែលអង្គុយនៅជួរមុខទាំងអស់ផងមុនគេ។ សម្រែកជ័យឃោសនី "ជយោគណបក្សសង្គ្រោះជាតិ" ឬក៏ "ជយោ សម រង្ស៊ី នឹង កឹម សុខា មនុស្សតែមួយ" ការប្តេជ្ញាចិត្តដ៏ខ្ជរខ្ជាវំជួយសាលដោយការទះដៃអបអរសាទរ, រួមទាំងសុន្ទរកថា លោកស្រី មួរ សុខហួរ ជាអនុប្រធានគណបក្សសង្គ្រោះជាតិពន្យល់យ៉ាងក្បោះក្បាយពីបុព្វហេតុនៃដំណើរមាតុភូមិនិវត្តន៍របស់មនុស្សរាល់លាននាក់ បានធ្វើឱ្យបរិយាកាសក្លាយជាឧឡារឹកជាអស្ចារ្យជាការងាយស្រួលនឹងទៅសង្គ្រោះប្រជាពលរដ្ឋដែលកំពុងរងគ្រោះ ដោយរបបផ្តាច់ការ ហ៊ុន សែន, បើទោះជាមិនបានពីពណ៌នា ថានឹងចាប់ ហ៊ុន សែន ឱ្យបានរបៀបណាក៏ដោយ ។

វេទិការសាធារណបានបញ្ចប់ទៅដោយជោគជ័យ រួចគេនាំគ្នាធ្វើការដង្ហែរក្បួនទៅតាមផ្លូវ "មេរីម៉ាក" សំដៅទៅកាន់សាលាក្រុងឡូវែល នាវេលាម៉ោងជាង៥ល្ងាចដូចគម្រោង ។



លោក សម រង្ស៊ី មិនបានមកវេទិកាសាធារណៈដោយផ្ទាល់ទេ



គណកម្មការចំពោះកិច្ចដំរូបសន្យារួមដំណើរមាតុភូមិនិវត្តជាមួយ សម រង្ស៊ី



ភ្ញៀវដែលមកវេទិកាសាធាណៈលោក សម រង្ស៊ី








# DIVERSITY
## ADULT DAYCARE CENTER

"ទីកន្លែងដែលអ្នកជាទីស្រលាញ់របស់លោកអ្នក អាចហៅថា ជាផ្ទះ"

**តើអ្វីទៅជាមជ្ឈមណ្ឌលថែទាំចាស់ជរា?**

យើងខ្ញុំយល់ឃើញថាក្នុងនាមជាអ្នកផ្តល់សេវាថែទាំពេញម៉ោង គឺជាការងារមិនងាយស្រួលនោះទេ។ នៅពេលពអ្នកជាទីស្រឡាញ់ដែលមានវ័យកាន់តែចាស់ ត្រូវការការថែទាំ រឺការមើលការខុសត្រូវក្នុងកំឡុង ពេលព្រឹក រឺពេលថ្ងៃនោះ វាអាចបង្កើតឱ្យមានអារម្មណ៍ស្មុកស្មាញដល់អ្នកមើលថែក្នុងគ្រួសារ។ គ្រួសារជាច្រើនគិតថាពួកគេគ្មានជម្រើសអ្វីក្រៅពីឈប់ធ្វើការងារ រឺឱ្យមានអ្នកមកមើលថែអ្នកដែលជា ស្រលាញ់របស់ខ្លួនដល់លំនៅដ្ឋាន រឺកន្លែងថែរទាំចាស់ជរា។ មជ្ឈមណ្ឌលថែទាំចាស់ជរា ដាយហ្វ័រស៊ីធី ដែលភាសាអង់គ្លេស Diversity Adult Daycare Center (DADC) មានផ្តល់ទីកន្លែងគ្រប់គ្រងដែលមានសុវត្ថិភាពដែលអ្នកដែលមានវ័យចំណាស់អាចធ្វើការទាក់ទងនឹងមនុស្សឯទៀត, រីករាយជាមួយនឹងសកម្មភាពផ្សេងៗ និងទទួលបានជំនួយថែទាំ។ ទីកន្លែងនេះវានឹងមិនធ្វើឱ្យលោកអ្នក ដែលជាអ្នកមើលការខុសត្រូវចំពោះពួកគាត់មានការបារម្ភអ្វីទាំងអស់ នៅពេលពួកគេមានការណាត់ជួប, ភារៈកិច្ចការងារ រឺមានពេលវេលាសម្រាប់ខ្លួនឯងខ្វាល់ផងដែរ។

**អត្ថប្រយោជន៍នៃសេវាថែទាំចាស់ជរា**

ចូលរួមជាមួយនឹងមជ្ឈមណ្ឌលថែទាំចាស់ជរា នឹងមានអត្ថប្រយោជន៍វិជ្ជមានជាច្រើនដល់ជនចាស់ជរា។ អ្នកជាទីស្រលាញ់ក្នុងគ្រួសាររបស់លោកអ្នកមិនចាំបាច់នៅផ្ទះដែលធ្វើឱ្យមានអារម្មណ៍ឯកកោរដោយគ្មានការជុំរុញលើកទឹកចិត្តផ្នែកស្មារតីនោះទេ នៅពេលអ្នកមើលថែទាំងពួកគាត់ជាប់រវល់។ ការមកកាន់មជ្ឈមណ្ឌលថែទាំចាស់ជរាបង្កើតឱ្យមាននូវអារម្មណ៍ថា ស្ថិតនៅក្នុងសហគមន៍មួយដែលពួកគាត់អាចមានភាពរីករាយ និងមាននូវសុខភាពល្អជាមួយនឹងសកម្មភាពជាច្រើននៅក្នុងមជ្ឈមណ្ឌល។ អ្នកជាទីស្រឡាញ់របស់លោកអ្នកនឹងទទឹមរង់ចាំក្នុងការទទួលបានឯករាជ និងជួបជាមួយនឹងមិត្តភ័ក្រ្ត។ មេត្រីភាពដែលលោកអ្នកមានជារៀងរាល់ថ្ងៃជំរុញឱ្យមានអារម្មណ៍នូវតំលៃខ្លួនឯង និងមិត្តភាព។

**សេវាកម្មដែលយើងខ្ញុំផ្តល់ជូននៅ DADC:**

- អាហារ នឹងនំចំណីបំប៉នច្រើន
- ថ្នាក់កីឡារជាក្រុម
- ថ្នាក់សម្រាប់ការសិក្សា
- ដំណើរកំសាន្ត និងការចេញទៅខាងក្រៅជាក្រុម
- ការលេងល្បែងកំសាន្ត និងសកម្មភាពរីករាយប្រចាំថ្ងៃ ជំនួយក្នុងការថែទាំ
- សេវាផាតមុខ និងធ្វើសក់
- ការដឹកជញ្ជូន
- ការរៀបចំកម្មវិធីខួបកំណើតប្រចាំខែ
- បុគ្គលិកផ្នែកពេទ្យ
- សកម្មភាពដាំបន្លែ

**តើនរណាជាបេក្ខភាពសមស្របសម្រាប់មជ្ឈមណ្ឌលថែទាំចាស់ជរា DADC**

- មានអាយុចាប់ពី ៥៥ និងចាស់ជាងនេះ
- ជនជាតិអាស៊ីអាគ្នេយ៍ និងស្ពឺនីស
- ទីតាំងយើងខ្ញុំងាយស្រួលសម្រាប់ជនពិការចេញចូលច

**របៀបនៃការបង់ប្រាក់ដែលយើងខ្ញុំទទួលយក**

- យើងខ្ញុំទទួលយកការបង់ប្រាក់ជាឯកជន
- ទទួកយករាល់ធានារ៉ាប់រងចំបងៗទាំងអស់

433 Elmwood Ave. Providence, R.I 02907
P: 401-427-1337 | F: 401-369-7818
www.diversityadc.com | diversityadc@gmail.com

**Se Habla Español**

យើងខ្ញុំនិយាយភាសាអង់គ្លេស, ស្ពេនីស, ខ្មែរ, ឡាវ, ម៉ោង, បំទុយក្កាល់, សូវៀត និងតាហ្គាលុក។ សូមអញ្ជើញមកទស្សនាកន្លែងមជ្ឈមណ្ឌលយើងខ្ញុំ។ យើងខ្ញុំនឹង ផ្តល់នូវការពិនិត្យវាយតំលៃ និងជំនួយក្នុងការដាក់ពាក្យដោយមិនគិតថ្លៃ។ ទទួលយករាល់ការធានារ៉ាប់រងចំបងៗ និងការទូទាត់ប្រាក់ជាឯកជនទាំងអស់។ សម្រាប់ធានារ៉ាប់រង មេឌីឃេត សម្រាប់សេវាថាទាំចាស់ជរាលោកអ្នកមិនចាំបាច់ចំណាយអ្វីទាំងអស់។

"អត្ថបទស្រាវជ្រាវប្រវត្តិសាស្ត្រ"

# ប្រវត្តិនៃសមាគមអ្នកសារព័ត៌មានខ្មែរ

(KJA = Khmer Journalist Association )

ដោយ ពិន សំខុន

តទៅលេខក្រោយ

តទៅបានប្រាក់ខែមិនត្រឹមតែតិចទេ ថែមទាំងមិនទៀងថែមទៀត។ សំណាងល្អ គេបានប្រពន្ធជាមនុស្សឆ្លាត សុច្ចរិត ហើយឧស្សាហ៍ណាស់ ខិតខំរកស៊ីលក់ដូរបន្ថែមការខ្វះខាតបានតាមពេល បន្ទាប់ពីពេលថែរកូន៤នាក់។

ក្នុងការឃោសនាឱ្យគណបក្សប្រជាធិបតេយ្យ ខ្ញុំបានប្រើធនធានផ្ទាល់ខ្លួន មួយខែ១ពាន់ដុល្លា គឺប្រាក់ដែលរដ្ឋគេបើកឱ្យខ្ញុំសម្រាប់អ្នករកការងារធ្វើនៅបន្ទាប់ពីខ្ញុំបានបាត់បង់ការងារនៅស្រុកបារាំង (Chomage)។ ប្រាក់នេះ ជាចំនួនច្រើនណាស់សម្រាប់ប្រើនៅកម្ពុជាដោយសារប្រាក់ជីវភាពប្រចាំខែរបស់អ្នករដ្ឋការ គេបើកបានតែ២០ដុល្លាក្នុង១ខែតែប៉ុណ្ណោះ។ បងប្រុសខ្ញុំឈ្មោះ ពិន សំផុន ជាអ្នកមានបន្ទុកផ្ញើរប្រាក់នោះ មកឱ្យខ្ញុំនៅកម្ពុជា។

ការឃោសនាបានប្រព្រឹត្តិទៅយ៉ាងរលូន ដោយសារកេរឈ្មោះលោកតា អ៊ិន តាំ ជាប្រធានគណបក្ស ១-លោកធ្លាប់មានស្នាដៃក្នុងការជួយបង្កើតរដ្ឋធម្មនុញ្ញថ្មី សម្រាប់ប្តូររូបភាពគ្រប់គ្រងពីរបបបក្សកុម្មុយនីស្ត"សាធារណរដ្ឋប្រជាមានិតកម្ពុជា" ទៅបង្កើតជា"រដ្ឋកម្ពុជា"វិញឱ្យស្របតាមទស្សនៈថ្មីនៃការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ ២-ធ្លាប់ជានាយករដ្ឋមន្ត្រីជំនាន់សម្តេចនរោត្តមសីហនុ៣-ធ្លាប់ជាប្រធានរដ្ឋសភាជាតិជំនាន់សាធារណរដ្ឋផង ៣-លោកតា អ៊ិន តាំ មានក្រុមគ្រួសារច្រើននៅខេត្តកំពង់ចាម ដែលលោកធ្លាប់ធ្វើជាចៅហ្វាយខេត្តនៅទីនោះទៀតផង។ ខ្ញុំបានចូលរួមកម្លាំងក្នុងគណបក្ស ដោយមាន



លោក អ៊ិន តាំ និងលោក ពិន សំខុន រូបថតកាលពីឆ្នាំ១៩៩៣

...នាឆ្នាំ១៩៩៣នៅ មិនមានសារព័តិមានខ្មែរអ្វីផ្សាយច្រើនទេ ក្រៅពីកាសែតៈ រស្មីកម្ពុជា ដែលធំជាងគេ បោះពុម្ពហើយដឹកពីប្រទេសថៃមកចែកចាយដល់អ្នកអាននៅកម្ពុជា ក្រៅពីនោះមានកាសែតខ្មែរ កោះសន្តិភាព កាសែតសេដ្ឋកិច្ច ជាកាសែតគាំទ្ររដ្ឋាភិបាល, នៅមានកាសែតយុវជន កាសែតមនសិការខ្មែរ ជាសែតប្រឆាំងនឹងនយោបាយរដ្ឋកម្ពុជា ក្រៅពីនោះក៏មានកាសែតបរទេសផ្សាយនៅក្នុងស្រុក មានThe Cambodia Daily, មាន Phnom Penh post, មាន Cambodia Time ទាំងអស់នោះជាកាសែតឯកជនដំបូងបង្អស់នៅកម្ពុជា, បើពីមុនមកទៀត មានអ្នកសរសេរប្រលោមលោក ដោយដៃគេ"កូពី"លក់ជាសាធារណៈមានប្រជាប្រិយភាពណាស់។ វិទ្យុនឹងទូរទស្សន៍មិនមានជាឯកជនទេ ទាំងអស់ជារបស់រដ្ឋដែលកាន់កាប់ដោយរដ្ឋាភិបាល ហ៊ុន សែន ។

ប្រជាពលរដ្ឋខ្មែរចូលចិត្តអានកាសែតណាស់ ព្រឹកៗឡើង គេអានកាសែតគ្រប់ៗគ្នា នៅតាមទីផ្សារ ផ្ទះកាហ្វេហាងលក់ចំណី ក្មេងៗរត់លក់កាសែតព្រោងព្រៀត...រោងពុម្ព៣-៤នៅភ្នំពេញ បោះពុម្ពកាសែត សៀវភៅ ឬខិតប័ណ្ណ យ៉ាងមមាញឹក ចំណេញប្រាក់បានក្រាស់ក្រែល។ អ្នកនយោបាយ គេបង្កើតកាសែតដែលការពារគណបក្សរបស់គេ ទាំងអស់នាំគ្នាបញ្ចេញមតិ ដោយគ្មានវិជ្ជាជីវៈជាអ្នកសារព័តិមានទេ ក្រៅតែពីកាសែតបរទេស។

ខ្លួនខ្ញុំដែលបានត្រឡប់ពីប្រទេសបារាំង ដែលធ្លាប់រស់នៅជិត២០ឆ្នាំ បានទៅដល់ភ្នំពេញ បានទៅរស់នៅផ្ទះប្អូនជីដូនមួយប្តីឈ្មោះ ឈន នឹងប្រពន្ធឈ្មោះ អាម៉េត ដើម្បីទៅចូលរួមជាមួយគណបក្សប្រជាធិបតេយ្យឈរឈ្មោះជាបេក្ខជនដំណាងរាស្ត្រឈរជើងនៅមណ្ឌលកំពង់ចាម ដែលជាតំបន់ចាស់ដែលខ្ញុំធ្លាប់រស់នៅ។ (នៅមានត)


KhmerPost USA, LLC
សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក



អគ្គនាយក សុបិន្ត ពិន
Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
sobenpin@khmerpost.us



និពន្ធនាយកខ្មែរ Khmer Editorial
និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
(978-942-1641| rogerpin@khmerpost.us



Richard Howe Jr.
Contributed Writer | Editor

ផ្សាយពាណិជ្ជកម្ម សុបិន្ត ពិន
Advertising Contact
Soben Pin
Cell: 979-656-8141
sobenpin@khmerpost.us

អ្នកនិពន្ធកិត្តិយស Staff Writer| Translator
Sokharath Koy

ច្នៃសោភ័ណ្ឌភាព Design Artist
Heng Chhun Leng

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter KhmerpostUSA

KhmerPost USA

Now Coming to California!

The state of California has the highest concentration of Cambodians in the country with over 35% residing in the greater Los Angeles area. According to the Census Bureau, there are **116,822 Cambodians** living in California, **41,459** in Los Angeles County, and **19,784** in the City of Long Beach.

With the expansion in California, **The KhmerPost USA** will bring relevant news and information, in both Khmer and English, in the **free** biweekly newspaper publication. We have the same commitment and dedication to our readers and advertisers that we have provided for the past 10 years to the Cambodian communities in New England.

- New Format! - Monthly Magazine Style
- Local News Relevant to the greater Long Beach Area
- Excellent Advertising Opportunities
- New Completive Rates!
- For additional information call: 714.486.3060

Celebrating 10 Years of Service

# REACH THOUSANDS OF PEOPLE IN THE CAMBODIAN COMMUNITY

## WITH COST EFFECTIVE NEWSPAPER ADVERTISING

KhmerPost USA




### DISTRIBUTION

*70+ Locations in Lowell, MA*
*7,000 copies per month*

*25 Locations in Lynn & Revere, MA*
*1,000 copies per month*

*25 Locations in Providence & Cranston, RI*
*2,000 copies per month*

### PUBLISHING

*Two Issues Every Month*

### READERSHIP

*50,000 Monthly*
*600,000 Annually*

**Khmer Post USA Distribution Locations Include:**

- Households
- Markets
- Retail Businesses
- Restaurants
- Office Buildings
- Government Offices
- Chamber of Commerce
- Buddhist Temples
- Laundromats
- And Much More

| 2019 PRINTING DATES | 2019 PRINTING DATES |
|---|---|
| 7Jan and 21 | 8 July and 22 |
| 4 Feb and 18 | 5 Aug and 19 |
| 4 March and 18 | 9 Sept and 23 |
| 8 April and 22 | 7 Oct and 21 |
| 6 May and 20 | 9 Nov and 23 |
| 10 Jun and 24 | 6 Dec and 20 |

*Advertising deadlines are 5 business days prior to printing date.*

### ADVERTISING RATES AND SIZES

*All ads are printed in Full Color*

| Ad Size (WxH) | 1 Issue | 3 Months (6 Issues) 5% Savings | 6 Months (12 Issues) 7.5% Savings | 12 Months (24 Issues) 10% Savings |
|---|---|---|---|---|
| **Full** (10" x 13") | $460 | $2,622 | $5,106 | $9,936 |
| **1/2** (10" x 6.5") | 310 | 1,674 | 3,441 | 6,696 |
| **1/4** (5" x 6.5") | 165 | 940 | 1831 | 3,564 |
| **1/8** (5" x 3.25") | 90 | 513 | 999 | 1,944 |

### CONTACT INFO

27 Jackson St. Unit 329 Lowell, MA 01852
**Tel: 978.677.7163 • Fax: 978.677.7092 • Email: sobenpin@khmerpost.us**
**www.khmerpost.us**

CELEBRATING 10 YEARS

*Khmer Post USA is a proud member of the Greater Lowell Chamber and Greater Merrimack Valley Convention and Visitors Bureau*

# ក្រុងខ្មែរឡូវែល: ប្រារព្ធខួបទី៣នៃរូបសំណាក ព្រហ្មបាយ័នដោយសមាគមក្រុងខ្មែរឡូវែល

ដោយ ពិន សំខុន

រូបសំណាកថ្មីមួយទៀត ទើបនឹងយកមកដាក់កាលពីថ្ងៃទី២២កញ្ញា កន្លងទៅ ដោយអ្នកស្រីប្រធានពង្សលក្ខិណាសាធុកានឹងគណកម្មការក្រុងខ្មែរ គឺជារូបចម្លាក់ថ្ម រចនាបទខ្មែរ មានឆ្លាក់អក្សរថា"ក្រុងខ្មែរឡូវែល"ដាក់ចំពីមុខផ្លូវចូលក្រុងខ្មែរនា"តំបន់ប៉ៃលិន"តែម្តង។ នៅលើបរិវេណដ៏តូចតែរូបចម្លាក់ខ្មែរក៏ច្រើន បានយកមកតាំងនៅទីនោះ ធ្វើឱ្យប្រជាពលរដ្ឋខ្មែរដែលរស់នៅទីនោះមានមោទនភាព នឹងរូបចម្លាក់នៃវប្បធម៌ខ្មែរ បានត្រូវយកមកបង្ហាញនៅទីសាធារណៈតំណាងឱ្យប្រជាជាតិមួយដែលធ្លាប់ថ្កុំថ្កើង ។


រូបសំណាកខ្មែរនៅផ្លូវចូលក្រុងខ្មែរ



រូបចម្លាក់ធំជាងគេ នៅចំកណ្តាល គឺព្រហ្មបាយ័នជាព្រះមុខ៤, នៅពីមុខអមទ្វារចូល មានរូបចម្លាក់ម្ខាងជារូបបដិមាករ"ជ័យវរ្ម័នទី៧"ជាអ្នកក៏សាងព្រហ្មបាយ័ន ហើយនឹងម្ខាងទៀតជារូប"ព្រះនាងឥន្ទ្រទេវី"មហេសីនៃព្រះបាទជ័យវរ្ម័នទី៧ នៅសងខាងជាបណ្តោយ មានរូបចម្លាក់ក្រុមយក្សនឹងក្រុមទេព្តា ទាញព្រ័តដណ្តើមយកទឹកអម្រឹតនៃជីវិត"អមតៈ"ទាំងនោះ សុទ្ធតែធ្វើពីថ្មភ្នំ ដែលធ្វើដោយថវិការសប្បុរសជនទាំងអស់ ។

ពីធីខួបកំណើតប្រព្រឹត្តទៅនៅថ្ងៃកាន់បិណ្ឌ នឹងមុនថ្ងៃបោះឆ្នោតក្រុមប្រឹក្សាក្រុង ធ្វើឱ្យមនុស្សម្នាមកចូលរួមរាប់ទាំងមន្ត្រីសាលាក្រុង ក្នុងសម្លៀកបំពាក់វប្បធម៌ខ្មែរយ៉ាងស្រស់ស្អាតជាហូហែរ តាំងពីព្រឹកដល់ល្ងាច តាមពីធីសាសនានឹងការរាំកំសាន្តកំដរដោយវង់តន្ត្រីសម័យមួយវង់នឹងមានទទួលម្ហូបចំណីខ្មែរពិសារផង ។










## ការិយាល័យច្បាប់
### រ៉ូសា និង តាំង


Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រ៉ូសា


Andrew 'Bunna' Taing, Esq.
មេធាវី អែន ឌ្រីវប៊ុណ្ណា តាំង

Law Office of
Rosa & Taing
ATTORNEY AT LAW

| SERVICES | តំណាងក្តីដូចខាងក្រោម |
| --- | --- |
| • Auto Accidents/ Personal Injury | • គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ |
| • Bankruptcy | • ក្ស័យធន |
| • Immigration | • អន្តោប្រវេសន៍ |
| • Consumer Protection | • ការពារអតិថិជន |
| • Real Estate Closings/Disputes | • ទំនាស់ផ្នែកអចលនវត្ថុ |
| • Divorces Child Custody | • លែងលះ និងអាណាព្យាបាលកិច្ច |

1550 Middlesex Street Lowell, MA 01851
Phone: **978-458-0934** | at@rosataing.com



ក្រុមហ៊ុនអចលនៈទ្រព្យ អឺប៊ឺន រាលអ៊ីស្តេក
## URBAN REAL ESTATE
មជ្ឈមណ្ឌលផ្តល់សេវាជួលលំនៅដ្ឋាន
Residential Leasing Center



ដាញ៉ែល តាន
ភ្នាក់ងារអចលនៈទ្រព្យ
**Daniel Tan**
Real Estate Agent
Cell: 978-902-6354

508 Westford Street • Lowell, MA 01851
(978) 454-0444



ក្រុមហ៊ុនធានារ៉ាប់រ៉ង ឃេឃេ អ៊ីនស្ហូរិន អេជេនស៊ី
## KK Insurance Agency, Inc.
រថយន្ត • លំនៅដ្ឋាន • អាជីវកម្ម
Car • Home • Business



508 Westford Street
Lowell, MA 01851
978-970-2212
kk@kkinsurancema.com

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
Home Care Agency
Group Adults Foster Care Program

***ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុម គ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។***

*At no Cost to you*

សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកដោយមិនគិតថ្លៃអ្នកនឹងត្រូវបានថែទាំដោយក្រុមបុគ្គលិកខ្មែរដែលមានវិជ្ជាជីវៈពី នើស (Nurse), Case Manager និង Home Health Aide បុគ្គលិកមានសណ្តានចិត្តល្អ ទន់ភ្លន់ និងមានការគោរពទំនៀមទំលាប់ខ្មែរ ។ បំរើសេវាក្នុងតំបន់ Lowell, Lynn, Revere, Boston និងតំបន់ជុំវិញ





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- *រស់នៅផ្ទះរដ្ឋ*
- *អាយុ ២២ ឆ្នាំឡើងទៅ*
- *មាសវ៉ែហិលស្តង់ដា*

**ផលប្រយោជន៍ទទួលបាន :**

- *ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយ ថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ*
- *ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក*
- *ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយ គ្រូពេទ្យ និងខេសមានីយើ*
- *វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់*
- *សមាជិកអាចទាក់ទងមក២៤ម៉ោង*

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ដើម្បីចុះឈ្មោះសូមទាក់ទងមក

To register, please contact:

Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# ពិធីបុណ្យសែនព្រះខែ

ដោយខ្មែរផុស

ពិធីបុណ្យសែនព្រះខែ រឺបុណ្យសែននំព្រះខែ គឺជាពិធីបុណ្យប្រពៃណីមួយយូរយាណាស់មកហើយ ដែលជនជនអាស៊ីជាពិសេសជនជាតិចិន, វៀតណាម និងប្រជាជានដែលមានសែស្រឡាយចិនទូទាំងពិភពលោកតែងតែប្រារព្ធធ្វើឡើងជារាងរាល់ឆ្នាំ។ ពិធីបុណ្យនេះជាទូទៅធ្វើឡើងនៅថ្ងៃទី១៥ ក្នុងខែសីហា នៃកាលបរិច្ឆេទចន្ទគតិរបស់ចិនដែលត្រូវនឹងថ្ងៃពេញបរមី។ សម្រាប់ឆ្នាំ២០១៩ នេះវិញ បុណ្យសែននំព្រះខែនេះគឺរៀបចំឡើងត្រូវនឹងថ្ងៃទី២៤ ខែកញ្ញានេះ។

ការសែនព្រះខែ គឺវាមានសារៈសំខាន់ណាស់ចំពោះប្រពៃណីជនជាតិចិន ហើយដើមទងដ៏វិញនឹងកម្មវិធីបុណ្យនេះមានខុសគ្នា។ បើតាមឯកសារមួយបានបញ្ជាក់ថា បុណ្យសែនព្រះខែនេះកើតឡើងតាំងពីសម័យរាជ្ជកាល ជូ ក្នុងរង្វង់ឆ្នាំ១០៤០-២៥៦ មុនគ្រិស្តសករាជមកម្លេះ ដោយរាជវង្សរបស់ចិន បានគោរពព្រះច័ន្ទនៅរដូវស្លឹកឈើជ្រុះដើម្បីបួងសួងឱ្យការប្រមូលផលដំណាំបានទទួលផលច្រើននៅឆ្នាំបន្ទាប់។ ពិធីបុណ្យនេះត្រូវបានប្រារព្ធធ្វើឡើងចាប់តាំងពីដើមរាជ្ជកាល ថាង ឆ្នាំ ៦១៨-៩០៧ មកម្លេះ។ វិធីសាមញ្ញបំផុតដើម្បីអបអរបុណ្យនេះ គឺតារយៈការបរិភោគនំព្រះខែ បើទោះបីជានំប្រភេទនេះផ្អែមមានចំនួនកាឡូរីខ្ពស់ប្រហែល៨00ក្នុងមួយនំដែលពិបាកក្នុងការហូបក៏ដោយ។

ការប្រារព្ធពិធីបុណ្យសែនព្រះខែនៅពាក់កណ្តាលរដូវស្លឹកឈើធ្លាក់នេះ ប្រារព្ធធ្វើនៅទូទាំងអាស៊ីខាងកើត រួមមានប្រទេសចិន, តៃវ៉ាន់, ជប៉ុន, សឹង្ហបូរី, កូរ៉េខាងត្បូង, ម៉ាឡេស៊ី, វៀត-ណាម និងហ្វីលីពីន។ ទោះជាយ៉ាងណាក៏ដោយ មកទល់នឹងបច្ចុប្បន្ននេះត្រូវបានគេសង្កេតមើលឃើញថា ក្រុមគ្រួសារនៅទូទាំងពិភពលោកបានចូលរួមកម្មវិធីនេះផងដែរដោយយកថ្ងៃនេះជាថ្ងៃឈប់សម្រាកមួយដោយបានធ្វើការជួបជុំគ្រួសារដើម្បីហូបអាហារពេលល្ងាច។



សម្រាប់ជនជនអាស៊ី គេតែងតែរៀបចំគ្រឿងសំណែនមានដូចជានំកន្ទក់ដែលធ្វើពីម្សៅសរាងដូចរង្វង់ដូចព្រះច័ន្ទ និងប្រភេទនំផ្សេងទៀតដូចជានំស្នូលង្វ៉ូវឃើញ ស្នូលពងទា, សណ្តែក, ផ្លែឈើ ឬគ្រាប់ឈូកដែលមានរាងមូល រឺបួនជ្រុងដោយត្រូវបានដុត រឺចំហុយដើម្បីជាតង្វាយ។ បន្ទាប់ពីសំណែនហើយ គេក៏តែងតែចែកនំព្រះខែមួយចំនួនទៅឱ្យសមាជិកគ្រួសារ, អ្នកជិតខាង រឺមិត្តរួមការងារជាដើម។ ជាទូទៅនេះប្រភេទនេះ បើបានហូបជាមួយតែក្តៅគឺកាន់តែប្រសើរ។

ជាងនេះទៅទៀត កម្មពិធីបុណ្យពាក់កណ្តាលរដូវស្លឹកឈើជ្រុះនេះ វាក៏គឺជាឱកាសមួយសម្រាប់ក្រុមគ្រួសារទាំងអស់ចំណាយពេលវេលាជាមួយគ្នាទោះបីពួកគេពុំមានទំនៀមទម្លាប់ជាក់លាក់ណាមួយក៏ដោយ។ សហគមន៍ជាច្រើនក៏បានចូលរួមធ្វើពិធីអបអរសាទរ ដោយមានបំភ្លើអំពូលភ្លើងក្រដាស ខណៈដែលអ្នកខ្លះទៀត នឹងចូលរួមរាំរបាំតោឬ ម៉ុងសាយ និងនាគនៅគេហដ្ឋានរបស់ពួកគេដើម្បីទទួលបានសំណាង។


ការិយាល័យ មេធាវី
ចំមាស ស្តាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com

សួនច្បារសាធារណៈនៅប៊ូសស្តុន
ដែលបានបង្កើតឡើងក្នុងឆ្នាំ១៨៣៧ គឺជាសួនច្បារសាធារណៈដំបូងគេនៅសហរដ្ឋអាមេរិក



Soben & Aiden Pin with Merle,
Photo by Samnang Toch-Chan

BOSTON PUBLIC GARDEN
Established in 1837, it was the first public botanical garden in America.

LEGEND
MOTOR GROUP, INC.
ហាងជួលជុលរថយន្ត លេជេន

មានសេវាជួលជុលរថយន្តគ្រប់ប្រភេទ
រយន្ត ប៉ះ បុក ខូចខាត និងក្រពិតមែន រឺទេ ?
ទូរស័ព្ទ 978-458-2085

COLLISION REPAIR
BEEN IN AN ACCIDENT?
FROM DENTS TO TOTALED,
WE CAN FIX IT ALL.



យើងរៀបចំសណ្តោងរថយន្ត នៅពេលត្រូវការ, ធ្វើការជាមួយនឹង
ក្រុមហ៊ុនធានារ៉ាប់រងរបស់លោកអ្នកនិងរៀបចំរាល់ឯកសារទាំងអស់។
ការពេញចិត្តរបស់លោកអ្នក គឺជាអាជីវកម្មរបស់យើង។

115 Rock St. Unt #7 Lowell, MA 01854

# Sunday is Fun Day at myLRTA

ថ្ងៃអាទិត្យគឺជាថ្ងៃដ៏រីករាយ
ជាមួយសេវាដឹកជញ្ជូនរបស់
អាជ្ញាធរដឹកជញ្ជូនតំបន់ឡូវែល




Relax. Ride. Enjoy.
លំហែកាយ. ដំណើរកំសាន្ត. ការរីករាយ

Take our new Sunday service
to exciting destinations across the region!
សូមធ្វើដំណើរជាមួយសេវាកម្មដឹកជញ្ជូនថ្មីថ្ងៃអាទិត្យ
ទៅកាន់គោលដៅដែលគួរឲ្យរំភើបទូទាំងតំបន់ឡូវ៉ែ

Shop. Dine. Explore.
ការទិញទំនិញ. ការទទួលទានអាហារ. ការស្វែងយល់អ្វីថ្មីៗ






Lowell Regional Transit Authority

**Visit LRTA.com**
**for Sunday Service Bus Schedules**
សូមចូលទៅកាន់វិបសាយ LRTA.com
សម្រាប់ពេលវាលានៃសេវាកម្មដឹកជញ្ជូនថ្ងៃ

Follow us on